# ការចិញ្ចឹម ( rearing )

គេត្រូវបញ្ឈប់ការឲ្យកំដៅ ក្រោយពីមាន់មានអាយុ៣សប្តាហ៍ ឬដើមរដូវដែលមានអាកាសធាតុក្តៅ។ អ្នកចិញ្ចឹមមាន់ធ្វើការជ្រើសរើសប្រព័ន្ធគ្រប់គ្រងផ្សេងៗគ្នា ។ ហ្វូងមាន់អាចត្រូវបានគេចិញ្ចឹម ដោយឲ្យដើររកស៊ីដោយខ្លួនឯង នៅខាងក្រៅ នៅកន្លែងដែលគេកំណត់ព្រំដែនដាក់ក្នុងទ្រុងធំ ក្នុងទ្រុងតូច រឺឃាំងនៅក្នុងទ្រុងចញ្ចឹមទាំងមូល ។

## គុណសម្បត្តិនៃការចិញ្ចឹមលែង រួមមាន :

- បន្ថយការចំណាយលើចំណីអាហារ ដោយឲ្យបក្សីទាំងនោះអាចដើររកស៊ីបានដោយខ្លួនឯង ដូចជារុក្ខជាតិបៃតងស្រស់, សត្វល្អិត និងកកាយស៊ីក្នុងលាមកសត្វពាហនៈធំៗ ។
- បន្ថយនូវចំណាយការសាងសង់ទ្រុង ។

## គុណវិបត្តិរួមមាន :

- បាត់បង់ដោយសត្វចង្រៃស៊ី
- ជំងឺឆ្លងបានដោយងាយពីតំបន់ គង្វាលសត្វដទៃៗទៀត ។ ការចិញ្ចឹមលែងដោយមានកំណត់ព្រំដែន ត្រូវការការគ្រប់គ្រងហ្វូងសត្វតិចតួច ។

គុណសម្បត្តិនៃការចិញ្ចឹមដាក់ទ្រុងធំ គឺអាចការពារបានច្រើនពីធាតុអាកាស និងសត្វចង្រៃផ្សេងៗ ។ គុណវិបត្តិរួមមាន ការចំណាយ និងការធានាប្រដាប់ប្រើប្រាស់ទាំងអស់ ចំណីមានជីវជាតិគ្រប់គ្រាន់ និងចំណាយលើការឲ្យចំណី ការធ្វើរបងការពារ និងបញ្ហាដែលកើតមានឡើង ដូចជាទ្រុងសើមនៅរដូវភ្លៀង ដែលជាមូលហេតុបណ្តាលឲ្យកើតមានជំងឺ និងបញ្ហាព្រូន ។

## ការចិញ្ចឹមដោយដាក់ទ្រុងតូចៗ (cages):

ទ្រុងតូចៗអាចសន្សំសំចៃផ្ទៃកំរាលបានច្រើន, និងបើសិនជាព្យួរខ្ពស់ពីដីអាចជៀសវាងការប៉ះពាល់នឹងលាមក, បក្សីត្រូវការការពារប្រឆាំងនឹងជំងឺផ្សេងៗ, ចៃ, និងប៉ារ៉ាស៊ីត ។ គេត្រូវចំណាយលើទ្រុងនេះយ៉ាងច្រើនពីដំបូង និងដែលចាំបាច់តំរូវឲ្យមានប្រព័ន្ធប្រមូលលាមកចោលផង ។

## ការចិញ្ចឹមដោយបង្ខាំង (confinement rearing):

ការចិញ្ចឹមបែបនេះអាចមានការការពារបានច្រើនពីសត្វចង្រៃ និងជំងឺផ្សេងៗ បើសិនជាមានវិធានការអានាម័យត្រឹមត្រូវ ដោយហាមមនុស្សចូលមើល មិនឲ្យមាន់ចាស់ៗ ឬសត្វចិញ្ចឹមលែង ឬកន្លាតចូលក្នុងទ្រុងឡើយ ។ សារធាតុចិញ្ចឹមសំខាន់ៗទាំងអស់ត្រូវបានគេផ្តល់ឲ្យសត្វដោយលាយក្នុង ចំណី ។ ចន្លោះលំហរដែលទុកសំរាប់សត្វនីមួយៗ គប្បីទុក ៦៥០ស.មការ៉េ ចំពោះសត្វដែលមានអាយុ៥សប្តាហ៍ដំបូង និងសំរាប់មាន់ធំត្រូវបង្កើនរហូតដល់ ២.៧៥០ស.មការ៉េ ។ កំរាលខាងក្រោម តាមធម្មតាគេក្រាលកំរាលកំរាស់ពី ៥ ទៅ១០ស.ម ។ ប្រភេទនៃកំរាលសម្រាប់ឲ្យសត្វដេកត្រូវបានគេជ្រើសរើសអាស្រ័យទៅតាមតំលៃ និងលទ្ធភាពដែលអាចរកបាននៅក្នុងស្រុក ។ សំភារៈដែលគេចូលចិត្តដាក់សំរាប់ជាកំរាលរួមមាន រុក្ខជាតិពុកផុយតូចៗ ចំបើងស្រូវចិញ្ច្រាំ ចំបើងចំណាំងឈើតូចៗ ឬអាចម៍ដែកឈូស អាចម៍រណា ( ប្រើបានតែ៤អាទិត្យតែប៉ុណ្ណោះ ) ចំរៀកសំបកត្នោត កំទេចស្នូលពោត ជួនកាលមានគ្រោះថ្នាក់ ដោយស្រមើល ) កំទេចសំបកសណ្តែកដី សំបកអំពៅ ក្រដាសកាសែត និងដីខ្សាច់ ( នេះជាការជ្រើសរើសចុងក្រោយ ) ។ ចំពោះកំរាលដែលមានគុណភាពមិនល្អ គេគួរធ្វើទ្រុងឲ្យបានធំបន្តិច ដើម្បីឲ្យកំរាលនោះស្ថិតនៅជាភាពស្ងួតជានិច្ច ។ ស្មៅចិញ្ច្រៀន ឬចំបើង ឬគ្រាប់ធញ្ញជាតិរឹង អាចបណ្តាលឲ្យសត្វកើតជំងឺ " ប៉ោងគែរ "ម្យ៉ាងវិញទៀតបើមាន់មានលក្ខណៈបែបនេះ គេគួរសំលាប់វាយកសាច់ ពីព្រោះមិនមានឱសថណាព្យាបាលបានឡើយ ។

# ប្រដាប់ដាក់ចាប់សត្វ គឺជាឧបករណ៍ដ៏មានប្រយោជន៍

ទំពួកសំរាប់ចាប់មាន់នេះ ជាឧបករណ៍មួយដែលមានប្រយោជន៍

1 – ទំពួកនេះ ធ្វើអំពីខ្សែឈួស រឺ សសៃដែក







២ – ទំពួកនេះ ប្រើសំរាប់ទាក់ជើងមាន់ៗ ចូរប្រយ័ត្ននៅពេលចាប់
និង ល្បួចចាប់វា ៗ



# ការថ្លឹងមាន់

## ថ្លឹងមាន់

1- ត្រួតពិនិត្យ ថ្លឹងទម្ងន់ និង កត់ត្រានៃការធ្វើ




2 - ប្រៀបធៀបការធ្វើ ជាមួយនិងគោលដៅ ដែលបានកំណត់

3 - វិភាគ និង ការធ្វើអោយវិធីសាស្ត្រផលិតកម្មកាន់តែរីកចំរើន

ក/ ជំងឺចោងតែ



ខ/ ការសំលាប់មាន់សំរាប់វះពិនិត្យក្រោយពេលសត្វងាប់



គ/ តំបន់ដែលត្រូវកាត់ចំពុះ




## ការចឹកគ្នា (cannibalism)

ការកាត់ចំពុះ គឺជាវិធីសាស្ត្រនៃការកាត់ ឬដុតចំពុះទាំងលើ ទាំងក្រោម ។ បើសិនជាការធ្វើដូច្នេះបានត្រឹមត្រូវល្អ គឺដើម្បីការពារកុំឲ្យសត្វចឹកស៊ីសាច់គ្នា ដែលជាទំលាប់អាក្រក់នៃការចឹករោម ឬចឹកដំបៅសត្វផ្សេងទៀត ។ អ្នកចិញ្ចឹមមាន់សាច់ និងមាន់ពងទាំងឡាយត្រូវអនុវត្តន៍នូវការកាត់ចំពុះមាន់

ទាំងអស់នៅ កន្លែងភ្ញាស់ ។ ចំពោះមាន់សាច់ គេត្រូវកាត់ប្រហែល ១/៣ នៃចំពុះនោះ ។ សំរាប់មាន់យកពងដែលរស់នៅរយៈពេលយូរ គេត្រូវកាត់ខាងលើ ១/៣ ទៅ ២/៣ និងកាត់ចំពុះខាងក្រោម ១/៤ ទៅ ១/៣ ។ បើសិនជាគេមិនអាចរកម៉ាស៊ីនកាត់ចំពុះបាន គេអាចប្រើកន្ត្រៃ ឬកាំបិតមុតក៏បាន ។ បើសិនជាមានចេញឈាមតិចៗ ត្រូវជ្រលក់ចំពុះដែលកាត់នៅស្រស់ៗនោះទៅក្នុងចំណី ។ មាន់ដែលចិញ្ចឹមលែង គួរតែកាត់ចំពុះ នៅពេលមានការចឹកគ្នាកើតឡើង ។ គួរជៀសវាងការកាត់ចំពុះជ្រៅពេក ។

វិធីសាស្រ្តមួយទៀតគឺការការពារកុំឲ្យចឹកគ្នា ជួនកាលគេត្រូវការផងដែរ ។ សញ្ញាដំបូង វាចឹកទាញរោមគ្នា ឬមានរហូតដល់ហូរចេញឈាម សត្វរងគ្រោះគួរដកចេញពីទ្រុង ។ ការចិញ្ចឹមមាន់ដោយប្រើពន្លឺព្រិលៗ ឬស្រអាប់ៗ ( ការចិញ្ចឹមក្នុងទ្រុងងងឹត ) គឺជាមធ្យោបាយមួយដ៏មានប្រសិទ្ធភាព គឺមានន័យថា គេអាចការពារបានពីការចឹកគ្នា ។ ទ្រុងចិញ្ចឹមនេះត្រូវការបង្អួចបន្តិចបន្តួច ប៉ុន្តែត្រូវមានកង្ហារបក់ចេញចូល និងផ្តល់ពន្លឺស្រអាប់ដោយដាក់ អំពូលភ្លើងតូចៗមួយចំនួន ។ បើគ្មានអំពូលភ្លើងទេ គេអាចប្រើទៀនក៏បាន ។ ចូរដាក់ស្នូកទឹក ស្នូកចំណីឲ្យបានច្រើន ដើម្បីការពារពីការបាត់បង់ជាតិទឹក និងបាត់បង់ទំងន់ក្នុងពេលងងឹត ។

(ដកស្រង់ចេញពី ខេមបូឌាអេចប្រេសញូស៍)